ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ASIAN INFRASTRUCTURE INVESTMENT BANK

# ផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាននិងសង្គម
# នៃអនុគម្រោងស្តារជួសជុលសាងសង់ផ្លូវ នៃខ្សែផ្លូវកញ្ចប់ទី២
## (ខ្សែផ្លូវគោកបន្ទាយ - កងមាស) ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង)


**សេចក្តីសង្ខេប**

រាជរដ្ឋាភិបាលកម្ពុជា ទទួលបានកម្ចីពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាហិរញ្ញប្បទាន នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ សម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីឆ្លើយតបទៅនឹងការរាលដាលជម្ងឺកូវីដ-១៩។ គម្រោងនេះអនុវត្តចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំ២០២៤ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នប្រត្តិបត្តិ ក្នុងខេត្តគោលដៅចំនួន៥ខេត្ត គឺខេត្តកំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ កោះកុងនិងខេត្តប៉ៃលិន។ គោលបំណងរបស់គម្រោងគឺដើម្បីទ្រទ្រង់ដល់ជីវភាពនិងសេដ្ឋកិច្ចនៅជនបទ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការរាលដាលជម្ងឺកូវីដ-១៩ និងការបន្សាំនឹងស្ថានភាពប្រែប្រួលធាតុអាកាស។ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ គឺតម្រូវអោយរៀបចំផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាន និងសង្គម។ លើសពីនេះ អ្នកទទួលការក៏ត្រូវរៀបចំផែនការសុវត្ថិភាពបរិស្ថាន និងសង្គម រួមបញ្ចូលទាំងផែនការសុខភាពនិងសុវត្ថិភាពការងារនិងយេនឌ័រ សម្រាប់អនុគម្រោងសាងសង់ផ្លូវជនបទ នៅតាមខេត្តគោលដៅ។

អនុគម្រោងខ្សែផ្លូវកញ្ចប់ទី២ (Lot 1: ខ្សែផ្លូវគោកបន្ទាយ - កងមាស) ស្ថិតក្នុងឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានប្រវែង ១២,៣៣០ម៉ែត្រ និងទទឹងផ្លូវប្រវែង៨ម៉ែត្រ បាននឹងកំពុងស្តារជួសជុលសាងសង់ឡើងវិញ ជាផ្លូវក្រាលកៅស៊ូពីរជាន់ និងបេតុងសរសៃដែក។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរួមមានដូចជា សំណង់លូមូលកាត់ផ្លូវចំនួន២១កន្លែង ក្នុងនោះសំណង់លូប្រអប់ចំនួន១កន្លែង និងសំណង់លូមូលចំនួន២០កន្លែង ត្រូវជួសជុលសាងសង់ឡើងវិញ។ អនុគម្រោងនេះចាប់ផ្តើមដំណើរការស្តារជួសជុលសាងសង់ ពីខែមិថុនា ឆ្នាំ២០២៣ រហូតដល់ខែឧសភាឆ្នាំ២០២៤ ដោយក្រុមហ៊ុន ស៊ីណូខនស្រ្តាក់សិន & អ៊ិនវេសមិន (C.NO Construction & Investment Co., Ltd) ជាអ្នកទទួលការសាងសង់ ដែលត្រូវចំណាយថវិកាអស់ ២,២៥៤,៦៧៤.៩៥ដុល្លាអាមេរិក។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃផែនការសុវត្ថិភាពបរិស្ថាននិងសង្គម គឺបានសិក្សានៅមុនពេលដំណើរការស្តារជួសជុលសាងសង់ផ្លូវ។ លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា ប្រជាពលរដ្ឋចំនួន៦៧គ្រួសារដែលស្ថិតនៅសងខាងផ្លូវ គឺទទួលរងផលប៉ះពាល់នៃការស្តារជួសជុលសាងសង់ផ្លូវនេះ។ ផលប៉ះពាល់បរិស្ថានដែលស្ថិតនៅសងខាងផ្លូវ រួមមាន ដើមត្នោត ដើមដូង ដើមអាកាស្យា និងដើមឈើហូបផ្លែមួយចំនួនទៀត និងរបងផ្ទះ ស្រយ៉ាបផ្ទះ អណ្តូងទឹកមួយកន្លែង និងជណ្តើរថ្មមួយ ដែលជាចំណីផ្លូវ។ ប្រជាពលរដ្ឋចំនួន៦៧គ្រួសារ បានឯកភាពនិងផ្តិតស្នាមមេដៃក្នុងការផ្តល់ដោយគ្មានសំណងនៃផលប៉ះពាល់ទាំងនោះ។ លើសពីនេះ រដ្ឋបាលស្រុករលាប្អៀរបានអះអាងបញ្ជាក់ជាលាយលក្ខ័អក្សរពីការមិនប៉ះពាល់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ការពិភាក្សាជាសាធារណៈចំនួន២លើកបានរៀបចំឡើង ក្នុងនោះការពិភាក្សាជាសាធារណៈលើកទី១ បានធ្វើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ៩១នាក់ (ស្ត្រី៥២នាក់) និងការពិភាក្សាជាសាធារណៈលើកទី២ គឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ មានប្រជាពលរដ្ឋចូលរួមចំនួន ៤៦នាក់ ក្នុងនោះមានស្ត្រី៣១នាក់។

ចំពោះយន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរផ្សេងៗ នៅក្នុងកំលុងពេលកំពុងសាងសង់គឺប្រជា-ពលរដ្ឋអាចផ្តល់ពត៌មាន ដែលពាក់ព័ន្ធនឹងការសាងសង់ផ្លូវ ដើម្បីបញ្ចៀសនូវការប៉ះពាល់ជាយថាហេតុណាមួយ។ យន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរ គឺអាចធ្វើឡើង ដោយការជូនជាពត៌មានតាមទូរស័ព្ទឬសរសេរជាលាយល័ក្ខអក្សរផ្តល់ជូនទៅកាន់អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ ឬមេភូមិ) ឬអ្នកទទួលការសាងសង់ ឬក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទ ឬក៏ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមដោះស្រាយ។ ចំពោះពត៌មានលម្អិតស្តីពីយន្តការបណ្តឹងតវ៉ា គឺមានបិទផ្សាយ និងរក្សាទុកនៅតាមសាលាឃុំ និងការដ្ឋានសាងសង់របស់អ្នកទទួលការ ដែលលេខទំនាក់ទំនងតាមគោលដៅនៃអនុគម្រោងនីមួយៗ។ ។